ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម
មកដល់ ថ្ងៃទី 25 ខែ 05 ឆ្នាំ 2016
លេខ 105
ម៉ោង ៧:៥

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៧/៧/២ កសក

រាជធានីភ្នំពេញ, ថ្ងៃទី...២៣...ខែឧសភា...ឆ្នាំ ២០១៦

**សូមជម្រាបជូន**
**ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទ**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ:** សំណើយកចិត្តទុកដាក់ឆ្លើយតប និងដោះស្រាយសំណូមពរប្រជាពលរដ្ឋតាមបណ្តាញព័ត៌មានសង្គម (ហ្វេសប៊ុក)។

**យោង:** - សេចក្តីណែនាំចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

- សេចក្តីសម្រេចលេខ០១៧ សសរ.កសក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ និងលេខ១១៥ សសរ.កសក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោក លោកស្រីប្រធានជ្រាបថា កន្លងមក ក្រសួងបានសម្រេចបង្កើតក្រុមការងារផ្សព្វផ្សាយព័ត៌មានតាមបណ្តាញសង្គម(ហ្វេសប៊ុក) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពថ្នាក់ដឹកនាំគ្រប់អង្គភាពក្រោមឱវាទ ដើម្បីផ្សព្វផ្សាយ និងផ្តល់ព័ត៌មានអំពីគោលនយោបាយសំខាន់ៗរបស់ក្រសួង និងបកស្រាយបំភ្លឺជូនសាធារណជនទូទៅពាក់ព័ន្ធសភាពការណ៍វិវត្តន៍នៃវិស័យកសិកម្ម និងការងារជំនាញរបស់អង្គភាព ព្រមទាំងបានបន្ថែមភារកិច្ចឲ្យតាមដាន និងស្រង់ព័ត៌មានបណ្តាញសង្គម(ហ្វេសប៊ុក)របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីឆ្លើយតប និងដោះស្រាយជូនប្រជាពលរដ្ឋទាន់ពេលវេលា។

រហូតដល់បច្ចុប្បន្ន ក្រសួងសង្កេតឃើញថា អង្គភាពភាគច្រើនពុំបានយកចិត្តទុកដាក់តាមដានបណ្តាញសង្គម(ហ្វេសប៊ុក)របស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** និងបណ្តាញសង្គម(ហ្វេសប៊ុក) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីបកស្រាយបំភ្លឺជូនសាធារណជនឲ្យបានទាន់ពេលវេលាឡើយ។ ដូចនេះ ស្នើឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពពង្រឹងការងារនេះឡើងវិញដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះមុខក្រសួង។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ ខ្ញុំសង្ឃឹមលើស្មារតីយកចិត្តទុកដាក់អនុវត្តតាមការណែនាំនេះពីគ្រប់អង្គភាពជាក់ជាមិនខាន។

សូមឯកឧត្តម លោក លោកស្រីប្រធានទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន:**
- ថ្នាក់ដឹកនាំក្រសួង
"ដើម្បីតាមដានការអនុវត្ត"
- ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320